# វិញឡុង

ស្ថាប័នរបស់បក្ខភាគបក្សកុម្មុយនិស្តវៀតណាមខេត្តវិញឡុង

ឆ្នាំទី ៣៩
ក្រាំងថ្មីលេខ 24 (1936)
ថ្ងៃ អង្គារ ទី ២៦ ខែកញ្ញា ឆ្នាំ ២០២៥
០៤ កើត ខែអស្សុជ ឆ្នាំម្សាញ់
សប្តស័ក ព.ស. ២៥៦៩


**ឈានដល់មហាសន្និបាតបក្ខភាគគ្រប់លំដាប់ថ្នាក់ អាណត្តិកាល ២០២៥-២០៣០**

## ជនរួមជាតិខ្មែរជឿជាក់ទៅលើការដឹកនាំរបស់បក្ស

(អាននៅទំព័រទី ២)

## ចែកអំណោយនិងពិនិត្យជំងឺដោយឥតគិតថ្លៃជូនមាមីងខ្មែរនាឱកាសបុណ្យសែនដូនតា

(អាននៅទំព័រទី ៦)

## លេខាសាខាបក្ស គិតគូរពីផលប្រយោជន៍ប្រជាជន



(អាននៅទំព័រទី ៤)

## ប្រធានគណៈកម្មការប្រជាជនភូមិ ជាស្ពានមេត្រីភាពរវាងគោលបំណងរបស់បក្ស និងទឹកចិត្តប្រជាជន



(អាននៅទំព័រទី ៥)

# ថ្នាក់ដឹកនាំខេត្តអញ្ជើញទៅសួរសុខទុក្ខ និងប្រសិទ្ធពរបុណ្យសែនដូនតាឆ្នាំ ២០២៥



*សមមិត្ត ហូធីហ្វាងអៀង-អនុលេខាអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សខេត្តសួរសុខទុក្ខ និងប្រគេនទេយ្យវត្ថុព្រះតេជព្រះគុណ យឿងវ៉ាំងណា-ព្រះពហុស្សុតវត្តចម្ប៉ាអង្គរជ័យ (ចំការ) ។ រូបថត៖* **ចាធី**

**កាល**ពីថ្ងៃទី ១៨ ខែកញ្ញា សមមិត្តហូធីហ្វាងអៀង-អនុលេខាអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សខេត្តចាត់តាំងគណៈប្រតិភូអញ្ជើញទៅសួរសុខទុក្ខ និងប្រសិទ្ធពរដល់ព្រះតេជព្រះគុណ យឿងវ៉ាំងណា-ព្រះពហុស្សុតវត្តចម្ប៉ា

(អានតទៅទំព័រទី ៨)

# ស្ងើចសរសើរសមូហភាព និងបុគ្គលឆ្នើមចំនួន ៨០ កន្លែងនិងនាក់ដំណាក់កាល ២០២០-២០២៥




*លោក ឡេវ៉ាំងហាំង អនុលេខាគណៈកម្មាធិការបក្សខេត្ត ជូនបណ្ណសរសើរដល់បណ្តាសមូហភាពឆ្នើម។ រូបថត៖* **ភៀកខ៊ា**

**កាល**ពីថ្ងៃទី ២២ ខែកញ្ញា គណៈកម្មាធិការរណសិរ្សមាតុភូមិវៀតណាមខេត្ត បានចាត់តាំងសន្និបាតគំរូឆ្នើមរបស់រណសិរ្សមាតុភូមិវៀតណាមនិងបណ្តាអង្គការចាត់តាំងនយោបាយ-សង្គមក្នុងខេត្តវិញឡុង ដំណាក់កាល ២០២០-២០២៥។

ក្នុងដំណាក់កាល ២០២០-២០២៥ ចលនាប្រឡងប្រណាំងស្នេហាជាតិរបស់រណសិរ្សមាតុភូមិវៀតណាម និងអង្គការនយោបាយ-សង្គមក្នុងខេត្ត បានអនុវត្តមានប្រសិទ្ធភាព ភ្ជាប់ជាមួយភារកិច្ចនយោបាយរបស់មូលដ្ឋាននីមួយៗ សម្រេចបានលទ្ធផល ដូចជា ការងារសុខុមាលភាពសង្គម ការកសាងជនបទថ្មី ទីក្រុងវប្បធម៌ ការបង្ការទប់ស្កាត់ជំងឺកូវីដ-១៩ និងការលើកកម្ពស់ ផែនមហាសាមគ្គីជនជាតិ។ ជាពិសេស ចំនួនទឹកប្រាក់ និងវត្ថុប្រមូលសម្រាប់គិតគូរដល់គ្រួសារក្រីក្រ និងធានាសុខុមាលភាពសង្គម រាប់ពាន់លានដុង។ បណ្តាចលនាកសាងជនបទថ្មី និងទីក្រុងអារ្យធម៌ សម្រេចគ្រប់វិស័យ។ ក្នុងនោះ ខេត្តត្រាវិញ (ចាស់) សម្រេចភារកិច្ចកសាងជនបទថ្មីនៅឆ្នាំ ២០២៤ វិញឡុង (ចាស់) មានឃុំ ១០០% សម្រេច បេនត្រែ (ចាស់) មានឃុំ ១២៨/១៥៧ សម្រេចលក្ខខណ្ឌជនបទថ្មី និងមានឃុំជាច្រើនទៀតបានទទួលស្គាល់ជាឃុំជនបទថ្មីលើកកម្ពស់ និងជនបទថ្មីខ្នាតគំរូ។

ប្រព័ន្ធសមាជិកអង្គការសម្ព័ន្ធ សមាជិកសមាគម បានអភិវឌ្ឍយ៉ាងរឹងមាំ ក្លាយជាកម្លាំងស្នូលក្នុងយុទ្ធនាការប្រឡងប្រណាំង។ បណ្តាអង្គការសាសនា និងប្រជាជនដែលនៅបរទេសក៏បានរួមចំណែកយ៉ាងសកម្ម និងសម្តែងការជិតជិត

(អានតទៅទំព័រទី ៤)

នាំយកគោលការណ៍ សេចក្តីសម្រេចចិត្តរបស់បក្សទៅក្នុងជីវភាព

# ជនរួមជាតិខ្មែរជឿជាក់ទៅលើការដឹកនាំរបស់បក្ស

**ឈាន**ដល់មហាសន្និបាតតំណាងបក្សភាគខេត្តលើកទី ១ អាណត្តិកាល ២០២៥-២០៣០ កម្មាភិបាល បក្ខជន និងប្រជាជនក្នុងខេត្តបានរួមមតិចំណង់ចំណូលចិត្តជាច្រើន។ ជាមួយនឹងស្មារតីសាមគ្គីទូទាំងប្រជាជាតិ សម្តែងនូវមតិចំណង់ចំណូលចិត្តជឿជាក់ បំណងប្រាថ្នាទៅលើអាណត្តិកាលថ្មីជាមួយនឹងបណ្តាការសម្រេចចិត្តនយោបាយដោយមានភាពទម្លុះទម្លាយ បង្កថាមពលសម្រាប់ខេត្តវិញឡុងអភិវឌ្ឍនយ៉ាងឆាប់រហ័ស សមស្រប ស្ថិរភាព។

* **ព្រះតេជព្រះគុណ សឺនង៉ុកហ្វិន** អនុប្រធានអចិន្ត្រៃយ៍សមាគមព្រះសង្ឃសាមគ្គីស្នេហាជាតិខេត្ត ព្រះចៅអធិការវត្តសង្ឃមង្គល (ឃុំទ្រុងថាញ់)៖ ជនរួមជាតិខ្មែរជឿជាក់ទៅលើការដឹកនាំរបស់បក្ស។

ជាមួយនឹងតួនាទីជាព្រះសង្ឃក៏ដូចជាមាមីងជនរួមជាតិខ្មែរក្នុងភូមិសាស្រ្តឃុំនិយាយដោយឡែក ខេត្តវិញឡុងនិយាយរួម អាត្មាមានក្តីរីករាយនឹងជឿជាក់ទៅលើការដឹកនាំរបស់គណៈកម្មាធិការបក្ស បណ្តាការរបស់រដ្ឋរណសិរ្សមាតុភូមិវៀតណាម មន្ទីរ ផ្នែកខេត្តនារយៈពេលកន្លង។ ជាពិសេសគឺ មានចំណង់ចំណូលចិត្តជឿជាក់ទៅក្នុងមហាសន្និបាតតំណាងបក្ខភាគខេត្តវិញឡុងលើកទី ១ សម្រេចជោគជ័យល្អប្រសើរ ហើយក្រោយពីមហាសន្និបាតនេះ ថ្នាក់ដឹកនាំខេត្តរួមជាមួយនឹងមន្ទីរ ផ្នែក មូលដ្ឋាននឹងបញ្ជូនសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតទៅក្នុងការអនុវត្តជាបន្ទាន់។ សាមីខ្លួនអាត្មាក៏ជាក់ក្តីសង្ឃឹម និងជឿជាក់ប្រាកដថាៈជាមួយនឹងការដឹកនាំរបស់ថ្នាក់ដឹកនាំខេត្ត ជាមួយនឹងរំហូរថាមពលថ្មី ខេត្តវិញឡុងនឹងអភិវឌ្ឍន៍យ៉ាងខ្លាំងក្លាក្នុងយុគសម័យថ្មី-យុគសម័យឈានទៀងរបស់ជនជាតិ។

* **សមមិត្ត ហ្វិញង៉ុកម៉ាយ** លេខាសាខាបក្សស្តីទីប្រធានភូមិអាងភូអា (ឃុំឡុងហោ)៖ គប្បីយកចិត្តទុកដាក់វិនិយោគហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន លើកកម្ពស់ប្រភពចំណូលជូនប្រជាជន។

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវសេចក្តីព្រាងឯកសារមហាសន្និបាតតំណាងបក្ខភាគខេត្តវិញឡុងលើកទី ១ ខ្ញុំមានចំណង់ចំណូលចិត្តជាមួយនឹងបណ្តាសមិទ្ធផលដែលសម្រេចបានក្នុងអាណត្តិកាលកន្លង ក៏ដូចជាការកំណត់គោលដៅចក្ខុវិស័យខាងមុខជាមួយនឹងបណ្តាភារកិច្ច វិធានការដើម្បីដាក់ចេញភារកិច្ចជាក់ស្តែង និងជិតដិតជាង សង្ឃឹមអាណត្តិកាលថ្មីខេត្តយើងនឹងអភិវឌ្ឍន៍យ៉ាងខ្លាំងក្លា។ ខ្ញុំសង្ឃឹមថា ខេត្តគប្បីបន្តយកចិត្តទុកដាក់កសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានព្រមៗគ្នា កសាងគមនាគមន៍ជនបទ ថែទាំសុខុមាលភាពសង្គម។ល។ ដោយឡែកតែវិស័យផលិតកសិកម្ម គប្បីកសាង និងពង្រីកទូលាយទម្រង់សេដ្ឋកិច្ចមានប្រសិទ្ធភាពជាច្រើនទៀត បង្កលក្ខណៈសម្រាប់ប្រជាជនបង្កើនប្រភពចំណូល ពង្រីកទូលាយទីផ្សារលក់ផលិតផល។

ជាមួយនឹងស្មារតីប្តេជ្ញាចិត្ត ពង្រីកលទ្ធផលដែលសម្រេចបានពីកម្លាំងផែនមហាសាមគ្គីនៅតំបន់អាសយជន ភូមិអាងភូ អានឹងបន្តខិតខំកសាងជនបទថ្មី រួមចំណែកលើកស្ទួយខេត្តយើងឈានដល់ភាពអភិវឌ្ឍន៍ឆាប់រហ័សរួមជាមួយនឹងទូទាំងប្រទេស។

* **សមមិត្ត ង្វៀងវ៉ាំងបែបា** កម្មាភិបាលចូលនិវត្តន៍សង្កាត់ឡុងចូវ៖ គប្បីយកចិត្តទុកដាក់ដល់ការងារកម្មាភិបាល បង្កបុព្វបទដើម្បីអភិវឌ្ឍន៍។

ខ្ញុំរីករាយណាស់ពេលបានដឹង និងបានពិនិត្យផ្ទៀងផ្ទាត់សេចក្តីព្រាងឯកសារជម្រាបជូនមហាសន្និបាតតំណាងបក្ខភាគខេត្តវិញឡុងលើកទី ១។ សាមីខ្ញុំតែងយកចិត្តទុកដាក់ដល់បណ្តាភារកិច្ច វិធានការសារវន្តដើម្បីអនុវត្តសេចក្តីសម្រេចចិត្តមហាសន្និបាតខាងមុខនេះ ជាពិសេសអំពីការងារកសាងបក្ស។ ខេត្តគប្បីយកចិត្តទុកដាក់ដល់ការងារបណ្តុះបណ្តាល បំពាក់បំប៉នកងជួរកម្មាភិបាល ជាពិសេសគឺ កម្មាភិបាលថ្នាក់ឃុំ សង្កាត់ ដើម្បីឆ្លើយតបតម្រូវការភារកិច្ចនយោបាយនាពេលបច្ចុប្បន្ន។ បញ្ជាក់ថា "កម្មាភិបាលគឺជាស្នឹងរបស់កិច្ចការគ្រប់យ៉ាង" អាណត្តិកាលថ្មី សង្ឃឹមថាខេត្តនឹងបន្តការបំពាក់បំប៉ន ហ្វឹកហ្វឺនដើម្បីលើកកម្ពស់គុណភាពកងជួរកម្មាភិបាល បង្កបុព្វបទដើម្បីអនុវត្តល្អភារកិច្ចនយោបាយអភិវឌ្ឍន៍ខេត្តយើង។ ទន្ទឹមនឹងនោះ គប្បីពង្រឹកតួនាទីរបស់រណសិរ្សមាតុភូមិ និងបណ្តាអង្គការមហាជននយោបាយ-សង្គមទៅក្នុងការឃ្លាំមើល និងប្រតិកម្មសង្គមរួមចំណែកកសាងបក្ស ជាពិសេសគឺ បង្កើនជាងទៀតការអនុវត្តន៍សេចក្តីសម្រេចចិត្តលេខ ២១៧ និងសេចក្តីសម្រេចចិត្តលេខ ២១៨ របស់ការិយាល័យនយោបាយ។ ទន្ទឹមនឹងនោះ ពង្រឹកតួនាទី បទពិសោធន៍ប្រិយភាពរបស់អ្នកមានវ័យចាស់ទៅក្នុងបណ្តាកិច្ចចលនា ចលនាបដិវត្តន៍របស់មូលដ្ឋាន។

ប្រែសម្រួល៖ **រតនា**




*ព្រះតេជព្រះគុណ សឺនង៉ុកហ្វិន។ រូបថត៖* **គៀកថា**



*សមមិត្ត ហ្វិញង៉ុកម៉ាយ។ រូបថត៖* **គៀកថា**



*សមមិត្ត ង្វៀងវ៉ាំងបែបា។ រូបថត៖* **គៀកថា**




*យុវជនខ្មែរមានស្ថានភាពលំបាកបានទទួលលំនៅឋានអំណោយបុណ្យសែនដូនតា។ រូបថត៖* **ង៉ុកសួង**

# ទិវាវប្បធម៌យុវជនខ្មែរអំណោយបុណ្យសែនដូនតា

**ព្រឹក**ថ្ងៃទី ២២ ខែកញ្ញា នៅវត្តជ្រោយទន្សា អង្គការសម្ព័ន្ធយុវជនខេត្ត និងសមាគមសហព័ន្ធន៍យុវជនវៀតណាមខេត្ត វិញឡុង ចាត់តាំងទិវាវប្បធម៌យុវជនជនជាតិខ្មែរអំណោយបុណ្យសែនដូនតាឆ្នាំ ២០២៥។

សមមិត្ត ចូវជីកុង អនុប្រធានគណៈឃោសនាអប់រំ និងប្រជាចលនា នៃគណៈកម្មាធិការបក្សខេត្ត បងង្វៀងថាញ់ញ៉ា អនុលេខាអង្គការសម្ព័ន្ធយុវជនខេត្ត និងជាប្រធានសមាគមសហព័ន្ធន៍យុវជនវៀតណាមខេត្ត វិញឡុង និង សមាជិកសម្ព័ន្ធយុវជនជាង ២០០ នាក់ចូលរួម។

ក្នុងពិធីនេះ តំណាងបានទស្សនាសិល្បៈ បង្ហាញអំពីអត្តសញ្ញាណវប្បធម៌ពិសេសរបស់ជនជាតិខ្មែរ ដោយយុវជន ក្នុងតំបន់សម្តែង បង្កើតការទំនាក់ទំនង និងតួនាទីរបស់យុវជនក្នុងការរក្សា និងអភិវឌ្ឍអត្តសញ្ញាណវប្បធម៌ជាតិ។ *(អានតទៅទំព័រទី ៨)*

## ស្ងើចសរសើរសមូហភាព និងបុគ្គលឆ្នើមចំនួន ៨០ កន្លែងនិងនាក់... (តមកពីទំព័រទី ១)

ជាមួយស្រុកកំណើត និងប្រទេសជាតិ។

លោក ឡេវ៉ាំងហាំង អនុលេខាគណៈកម្មាធិការបក្សខេត្ត ប្រធានគណៈកម្មាធិការរណសិរ្សមាតុភូមិវៀតណាមខេត្តវិញឡុង បានចង្អុលការដល់បណ្ដាថ្នាក់ បណ្ដាផ្នែក សមាជិកគណៈកម្មាធិការរណសិរ្សមាតុភូមិវៀតណាម ក្នុងរយៈកាលខាងមុខនេះ បន្តបំផុសចលនាប្រឡងប្រណាំងស្នេហាជាតិទូលំទូលាយក្នុងប្រជាជនគ្រប់ជាន់ស្រទាប់។ បណ្ដាចលនាប្រឡងប្រណាំងត្រូវភ្ជាប់ជាមួយភារកិច្ចនយោបាយ របស់បណ្ដាថ្នាក់ បណ្ដាផ្នែក និងអង្គភាព សមូហភាពនីមួយៗ ជាពិសេសអនុវត្តល្អចលនាកម្មវិធីកាត់បន្ថយអត្រាគ្រួសារក្រីក្រចីរភាព កសាងជនបទថ្មី កសាងទីក្រុងអារ្យធម៌ បំផុសចលនាប្រឡងប្រណាំងបធានបទ ប្រមូលផ្តុំលើកិច្ចការសំខាន់ ជាបន្ទាន់ ដើម្បីពង្រីកសេដ្ឋកិច្ច–សង្គម គិតគូរដល់ជីវភាព សិទ្ធិនិងផលប្រយោជន៍ស្របច្បាប់របស់ប្រជាជន សមាជិកអង្គការសម្ព័ន្ធ សមាជិកសមាគម។

ទន្ទឹមនឹងនោះត្រូវកែប្រែខ្លឹមសារប្រឡងប្រណាំង កែប្រែរូបភាពចាត់តាំងឲ្យបានសម្បូរបែប ចាត់តាំងបំផុសចលនាដោយរបៀបប្រឡងប្រណាំងសម្បូរបែប ឆ្ពោះទៅកាន់មូលដ្ឋាន ផ្តុំអនុវត្តឱ្យមានផលក្នុងការអនុវត្តន៍ចលនាប្រឡងប្រណាំង។ យកចិត្តទុកដាក់ល្អ បំផុសចលនាដល់ប្រជាជនគ្រប់ជាន់ស្រទាប់ សាសនា និងប្រជាជននៅបរទេស ចូលរួមប្រឡងប្រណាំង។ ទន្ទឹមនឹងនោះ អនុវត្តសហការប្រមូលប្រភពកម្លាំងស្ថិរភាព។

សន្និបាត បានស្ងើចសើរសមូហភាព និងបុគ្គលឆ្នើម ៥០ កន្លែង និងនាក់ ពីរណសិរ្សមាតុភូមិវៀតណាម និងបណ្ដាអង្គការនយោបាយ–សង្គម គ្រប់លំដាប់ថ្នាក់។ សមូហភាព បុគ្គលចំនួន ៣០ កន្លែង និងនាក់ ទទួលបាន បណ្ណសរសើររបស់ប្រធានគណៈកម្មាធិការប្រជាជនខេត្ត៕



*ពិធីជូនបណ្ណសរសើររបស់ប្រធាន គណៈកម្មាធិការប្រជាជនខេត្ត ដល់សមូហភាព បុគ្គល។ រូបថត៖* **ឡៀកខ៉ា**

ប្រែសម្រួល៖ **សុខា**

# លេខាសាខាបក្ស គិតគូរពីផលប្រយោជន៍ប្រជាជន

*លោក សឺនម៉ីយឿង (កើតឆ្នាំ ១៩៥៦) បច្ចុប្បន្ន ជាលេខាសាខាបក្ស និងជាប្រធានគណៈកម្មការប្រជាជនអនុសង្កាត់អង្គលី ២ សង្កាត់ដុងថាញ់។ លោកបានប្រជាជនគោរពស្រឡាញ់ ពីព្រោះលោកតែងគិតគូរពីផលប្រយោជន៍ប្រជាជន បំពេញកិច្ចការជូនប្រជាជនដោយអស់ពីចិត្ត។*


*លោក សឺនម៉ីយឿង សំណេះសំណាលជាមួយព្រះសង្ឃវត្តអង្គលីជើង។*

**កាល**ដូចជាបណ្ដាយុវជនដទៃ ពេលធំដឹងក្ដី នៅឆ្នាំ ១៩៧០ យុវជនម៉ីយឿង បានចូលបួសរៀននៅវត្តអង្គលីជើង។ ឆ្នាំ ១៩៧៥ ក៏បានលាផ្នួសមកជាគ្រហស្ថ។ ក្រោយរយៈពេលលាចាកសិក្ខាបទបាន ២ ខែក៏បានចូលបំពេញការងារជាកងឈ្លបនៅមូលដ្ឋាន។ ឆ្នាំ ១៩៩២ លោកបានទទួលនាទីជាប្រធានគណៈកម្មការប្រជាជនភូមិ។ លុះដល់ឆ្នាំ១៩៩៦ លោកបានយុំទទួលយកឡើងបំពេញការងារក្នុងសមាគមកសិករ កម្មាភិបាលកសិកម្ម ក្រុមប្រឹក្សាប្រជាជន រណសិរ្ស។ ឆ្នាំ ២០១៦ លោកទទួលបានរបបចូលនិវត្តន៍។ ពិនិត្យឃើញលោកមានសមត្ថភាព និងមានប្រជាប្រិយភាពជាមួយមូលដ្ឋាន ឆ្នាំ ២០១៧ លោកបានបោះឆ្នោតជាលេខាសាខាបក្ស និងជាប្រធានគណៈកម្មការប្រជាជនភូមិអង្គលី ២ រហូតដល់មកអនុសង្កាត់អង្គលី ២ នាពេលបច្ចុប្បន្ន។

ពេលដែលលោកវិលមកទទួលនាទីជាលេខាសាខាបក្សភូមិ ជាពេលដែលជីវភាពប្រជាជននៅមានការខ្សត់ខ្សោយ ហេដ្ឋារចនាសម្ព័ន្ធនៅមានការលំបាក ប្រជាជនបានប្រសព្វជាមួយចំណេះដឹងក៏ស្តួចស្តើង អត្រាគ្រួសារក្រីក្រនៅខ្ពស់។ល។ បន្ទាប់មក លោករួមជាមួយបណ្ដាផ្នែកអង្គការមហាជន និងបណ្ដាបក្ខជននៅក្នុងភូមិផ្ទៀងផ្ទាត់កិច្ចការអ្វីសំខាន់ត្រូវធ្វើមុន សំណង់ណាចាំបាច់ត្រូវកសាង ចំណេះដឹងណាត្រូវបានហ្វឹកហាត់។ល។ដើម្បីឱ្យភូមិមានការរីកចម្រើនផង ជីវភាពប្រជាជនបានលើកកម្ពស់ផង រួចស្នើទៅថ្នាក់មានសិទ្ធិអំណាចដើម្បីដោះស្រាយ។ ផ្ដើមពីនោះ កម្មវិធី គម្រោងការជាច្រើនក៏បានវិនិយោគទុនកសាងជាបន្តបន្ទាប់ បណ្ដាថ្នាក់ហ្វឹកហាត់ចំណេះដឹងវិទ្យាសាស្ត្របច្ចេកទេសក៏បានចាត់តាំងញឹកញាប់ ជួយឱ្យប្រសិទ្ធភាពខាងការផលិត ចិញ្ចឹមសត្វរបស់ប្រជាជននិយាយរួម ជនរួមជាតិខ្មែរនិយាយដោយឡែកកាន់តែមានប្រសិទ្ធភាពជាង កម្រិតប្រាក់ចំណូលរបស់ប្រជាជនក្នុងភូមិក៏បានកើនឡើង។ គិតមកទល់ពេលនេះ ភូមិគ្មាននៅមានគ្រួសារក្រីក្រទៀតឡើយ នៅមានគ្រួសារជិតក្រតែចំនួន ៤ គ្រួ។ ភូមិសម្រេចគោលដៅបំបាត់ផ្ទះបណ្ដោះអាសន្ន ផ្ទះទ្រុឌទ្រោម។

លោក សឺនម៉ីយឿង សំណេះសំណាល៖ រលឹកមកវិញពីអតីតកាលពេលជីវភាពប្រជាជននៅមានការលំបាកខ្លាំងខ្ញុំសែនក្តុកក្តួល។ ពេលនេះប្រជាជនបានកក់ក្ដៅសម្បូរសប្បាយ ផ្ទះសម្បែងបានរឹងមាំ កូនចៅបានជិះទោចក្រយានលើដងផ្លូវល្អល្អះ រឹងមាំ អគ្គិសនី ទឹកស្អាតក៏ប្រជាជនបានអាស្រ័យផល ធ្វើឱ្យខ្ញុំមានអារម្មណ៍រីករាយយ៉ាងខ្លាំង។

លោកគឺជាបង្អែកក្នុងគ្រួសារ ហើយក៏ជាគំរូក្នុងការពង្រីកសេដ្ឋកិច្ច។ គ្រួសារលោក មានកម្មសិទ្ធិដីធ្លីជាង ០១ ហិកតា ពេលដែលកូនមានប្ដីប្រពន្ធចេញរស់នៅដោយឡែក លោកបានចែកឱ្យមានចំណែកស្មើៗគ្នា លោកទុកតែចំនួន ០,៤ ហិកតាប្រើប្រាស់ឱ្យការដាំឈើហូបផ្លែ ដោយក្នុងមួយឆ្នាំៗទទួលបានប្រាក់ចំណូលពីចម្ការឈើហូបផ្លែប្រមាណ ១៥០-១៦០ លានដុង។ ដោយទទួលរ៉ាប់រងបានល្អតួនាទីជាលេខាសាខាបក្ស អនុវត្តល្អការងារដែលបានប្រគល់ជូន និងសង្វាតក្នុងការងារពលកម្ម ផលិត គ្រួសារលោកក៏មានលក្ខណៈចិញ្ចឹមកូន ៣ រូបរៀនសូត្រសម្រេចតាមគោលដៅ រួចកូនទាំង ៣ នាក់ក៏បានបញ្ចប់ការសិក្សាមានការងារធ្វើលំនឹង។

អំពីការបំផុសចលនាប្រជាជនចូលរួមកសាងបណ្ដាសំណង់ផលប្រយោជន៍សង្គម លោកតែងធ្វើជាអ្នកឈានមុខដើម្បីប្រជាជនយកតម្រាប់តាម។ ជាក់ស្តែងដូចជាផ្សព្វផ្សាយកសាងសំណង់ផ្លូវតមនាគមន៍លើភូមិសាស្ត្រអនុសង្កាត់ មានដីជាច្រើនបានប៉ះពាល់ ក្នុងនោះមានដីរបស់គ្រួសារលោករងការប៉ះពាល់ច្រើនបំផុត ក៏បានលោកបរិច្ចាគប្រមាណ ១.០០០ ម៉ែត្រក្រឡា តិតជាតម្លៃជាង ២០០ លានដុងដើម្បីសំណង់បានដំណើរការ។ ប្រជាជនដទៃទៀត ពេលឃើញលោកធ្វើជាគំរូបរិច្ចាគដូច្នោះ រីឯខ្លួនក៏មានដីប៉ះពាល់តិចជាងក៏យល់ព្រមបរិច្ចាគតាមដែរ។

សាខាបក្សអនុសង្កាត់អង្គលី ២ មានបក្ខជនចំនួន ១២ រូប ក្នុងនោះមានបក្ខជនខ្មែរចំនួន ១០ រូប។ រ៉ាប់រងតួនាទីជាលេខាសាខាបក្សភូមិ លោករួមជាមួយបក្ខជនដទៃទៀត ពង្រីកល្អស្មារតីសាមគ្គីអនុវត្តសម្រេច និងលើសបណ្ដាភាគកម្រិត សេចក្តីសម្រេចចិត្ត។ អាស្រ័យហេតុនោះ ជារៀងរាល់ឆ្នាំ សាខាបក្សទទួលបានការវាយតម្លៃ "សម្រេចឆ្នើមភារកិច្ច"។

សម្គាល់ឃើញថា វត្តជាមជ្ឈដ្ឋានផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាព ម្ល៉ោះហើយលោកសឺនម៉ីយឿងតែងសហការជាមួយព្រះសង្ឃ គណៈអាចារ្យអាភិបាលវត្តអនុវត្តការផ្សព្វផ្សាយដើម្បីជួយឱ្យជនរួមជាតិខ្មែរ ប្រតិបត្តិល្អគោលការណ៍ គោលមាគ៌ារបស់បក្ស គោលនយោបាយ ច្បាប់របស់រដ្ឋ បដិសេធជាមួយបណ្ដាទ្រឹស្តីមួលបង្កាច់របស់បណ្ដាអានុភាពជាអមិត្ត លំនឹងស្ថានភាពសន្តិសុខនយោបាយ សន្តិសុខសណ្ដាប់ធ្នាប់សង្គមលើភូមិសាស្ត្រអាសយជន។

លោក ឡេមិញទ័រ ប្រធានគណៈកម្មាធិការប្រជាជនសង្កាត់ដុងថាញ់ មានប្រសាសន៍ឱ្យដឹង៖ ជាអ្នកធ្លាប់ឆ្លងកាត់ឋានៈនាទីជាច្រើន ម្ល៉ោះហើយលោកម៉ីយឿង មានបទពិសោធន៍ជាច្រើន ក្នុងនោះ មានមេរៀនជិតស្និទ្ធជាមួយប្រជាជនបានលោកសម្តែងឃើញច្បាស់បំផុត។ អាស្រ័យហេតុនោះ រាល់ការងារបំផុសចលនារបស់លោក ក៏មានភាពងាយស្រួលជាង។ ចាប់ពីពេលលោកទទួលនាទីជាលេខាសាខាបក្ស និងជាប្រធានគណៈកម្មការប្រជាជនភូមិអង្គលី ២ និងរហូតដល់អនុសង្កាត់អង្គលី ២ លោកបំផុសចលនាកសាងបានសំណង់សាធារណប្រយោជន៍ជាច្រើន ជួយឱ្យអនុសង្កាត់ដែលមានជនរួមជាតិខ្មែរជាង ៦២% មានភាពវិវឌ្ឍន៍យ៉ាងច្បាស់។

លោក សឺនម៉ីយឿង ទទួលបានការស្ងើចសរសើរដោយបណ្ដាបណ្ណាស្នាដៃតាំងពីមូលដ្ឋានរហូតដល់មជ្ឈិម៖ ឆ្នាំ ២០២២ លោកបានគណៈកម្មាធិការប្រជាជនខេត្តជូនបណ្ណសរសើរអំពីស្នាដៃសកម្មក្នុងការចូលរួមកសាងជនបទថ្មី។ ឆ្នាំ ២០២០ លោកបានជ្រើសស្ងើចសរសើរក្នុងមហាសន្និបាតប្រឡងប្រណាំងស្នេហាជាតិទូទាំងប្រទេសដែលបានចាត់តាំងឡើងនៅទីក្រុងហាណូយ។ ទទួលបានសញ្ញាសម្គាល់អាយុបក្ស ៣០ ឆ្នាំ រួមជាមួយបណ្ដាស្នាដៃដទៃទៀត៕

អត្ថបទ-រូបថត៖ **សម្បត្តិ**


*លោក សឺនម៉ីយឿង ថែទាំចម្ការក្រូចរបស់គ្រួសារ។*

# ប្រធានគណៈកម្មការប្រជាជនភូមិ ជាស្ពានមេត្រីភាពរវាងគោលបំណងរបស់បក្ស និងទឹកចិត្តប្រជាជន

*សួររកលោក គីមសុភាព ប្រជាជនភូមិបត់ថែក ឃុំសុងឡុក នរណាក៏ស្គាល់ និងស្ងើចសរសើរលោកជាគំរូកម្មាភិបាលជិតដិតជាមួយប្រជាជន អស់ពីចិត្តចំពោះការងារ។ មាមីងនៅទីនេះ តែងស្ងើចសរសើរលោក "ជាស្ពានមេត្រីភាពរវាងគោលបំណងរបស់បក្ស និងទឹកចិត្តប្រជាជន" ផង ជាអ្នករួមដំណើរជាមួយប្រជាជនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចផង។*



*លោកគីមសុភាព។*

**ភូមិ**បត់ថែកមានគ្រួសារប្រជាជនជាង ៤២០ គ្រួសារ ក្នុងនោះគ្រួសារជនរួមជាតិខ្មែរជិត ៩០%។ មាមីងជនរួមជាតិខ្មែរនៅទីនេះតែងចងចាំជានិច្ចនៅពេលមូលដ្ឋានដំឡើងប្រព័ន្ធបង្គោលភ្លើងតាមដងផ្លូវ លោកគីមសុភាពជាអ្នកចំណាយថវិកាដំឡើង ៥ បង្គោលមុនជាងគេបំផុត។ ការធ្វើជាគំរូនោះហើយទើបគ្រួសារប្រជាជនជាច្រើនធ្វើតាម ចូលរួមកសាងបង្គោលភ្លើងអុចបំភ្លឺតាមដងផ្លូវនៅជនបទ។

**នាំយកគោលការណ៍ទៅក្នុងជីវភាព**

មិនត្រឹមតែគិតគូរពីសុខុមាលភាពសង្គមប៉ុណ្ណោះទេ លោកសុភាព នៅទាំងជាអ្នកសកម្មក្នុងការចលនាប្រជាជនអនុវត្តបណ្ដាលក្ខខណ្ឌលំបាកក្នុងការកសាងជនបទថ្មីទៀតផង។ លោកតែងចលនាប្រជាជនឲ្យដាក់កញ្ចប់ បំពង់ថ្នាំការពាររុក្ខជាតិនៅកន្លែងដែលបានកំណត់ រក្សាសកម្មភាពភ្លឺបបរិស្ថាន។ តាមរយៈនោះដោះស្រាយបានល្អបញ្ហាកខ្វក់បរិស្ថាននៅលើភូមិសាស្ត្រភូមិ។

នៅឆ្នាំ ២០២៣ លោកបំផុសចលនាប្រជាជនជិត ៤០ គ្រួសារ ចូលរួមបរិច្ចាគដី និងសម្ភារកសិកម្ម ដើម្បីកសាងសាងផ្លូវ ២ ខ្សែ និងស្ពានជនបទ ១ កន្លែង បង្កលក្ខណៈឲ្យមាមីងធ្វើដំណើរបានងាយស្រួលផង ពង្រីកពាណិជ្ជកម្ម កែលម្អជីវភាពផង។

លោកថាច់ឡេ អ្នកមានប្រជាប្រិយភាពចូលរួមបរិច្ចាគដីជាង ៧០០ ម៉ែត្រក្រឡា សំណេះសំណាល៖ "ចំពោះខ្ញុំនៅពេលកសាងផ្លូវ ស្ពាន ដើម្បីប្រជាជនកែលម្អជីវភាព ខ្ញុំតែងស្ម័គ្រចិត្តចូលរួមជានិច្ច។ ប្រសិនបើគ្មានលោកសុភាព ព្យាយាមចលនា ពន្យល់មាមីងឲ្យយល់នោះទេ ពិតជាមាមីងមិនយល់ស្រប ហើយចូលរួមកុះករដូច្នេះឡើយ"។

**ជាកម្លាំងស្នូលក្នុងការសាមគ្គី បំផុសចលនា**

លោកគីមសុភាព មិនត្រឹមតែជាអ្នកចលនាប៉ុណ្ណោះទេ នៅទាំងជាអ្នកចូលរួមដោយផ្ទាល់ជាមួយប្រជាជនក្នុងបណ្ដាចលនាដូចជា៖ អនាម័យបរិស្ថាន ដាំផ្កាតាមដងផ្លូវ ឧបត្ថម្ភគ្រួសារក្រីក្រ កសាងផ្ទះមេត្តាធម៌ជាដើម។ របៀបដែលលោក "ធ្វើផ្ទាល់ដៃ" កាន់តែមានភាពសាយភាយយ៉ាងទូលំទូលាយ។ អាស្រ័យហេតុនោះ ទើបភូមិបត់ថែករីកចម្រើនខ្លាំង៖ ផ្លូវធំៗ និងផ្លូវលំក្នុងភូមិបានកសាងរឹងមាំ ប្រព័ន្ធធារាសាស្ត្រក៏បានជីកស្តារ មានប្រភពទឹកគ្រប់ចំនួនសម្រាប់ផលិតកសិកម្ម។

**ធ្វើជាគំរូទាំងពីរពង្រីកសេដ្ឋកិច្ចគ្រួសារ**

ជីវភាពគ្រួសារប្រជាជនផ្សារភ្ជាប់នឹងវិស័យកសិកម្ម ម្ល៉ោះហើយ លោកគីមសុភាព តែងសំណេះសំណាល ស្ដាប់យោបល់ និងណែនាំមាមីងបង្វែរការផលិតឲ្យសមស្រប។ រូបលោកផ្ទាល់ក៏ជាគំរូក្នុងការផ្ដើមអាជីវកម្មពីដីស្រែមួយចំនួនដែលឪពុកម្ដាយលោកចែកឲ្យ។ លោកបង្វែរផ្ទៃដីស្រែមិនសូវបានផលមកដាំដូងសរីរាង្គ សន្សំសំចៃទុនទិញគោចិញ្ចឹម និងទិញស្រែបន្ថែម។ គិតមកទល់ពេលនេះ គ្រួសារលោកមានដី ៣ ហិកតា ដូលថែម ២ ហិកតា សម្រាប់ធ្វើវប្បកម្ម និងចិញ្ចឹមគោជាង ១០ ក្បាល ទទួលបានប្រាក់ចំណូលជិត ៣០០ លានដុងក្នុងមួយឆ្នាំ។

ពិសេសជាងទៀត គាត់តែងស្ម័គ្រចិត្តចែករំលែកបទពិសោធន៍ជូនមាមីងក្នុងភូមិ ជំរុញទឹកចិត្តមាមីងឲ្យអនុវត្តតាមវិទ្យាសាស្ត្រ បច្ចេកទេសជឿនលឿនក្នុងការផលិត។ អាស្រ័យហេតុនោះ ទើបមានគ្រួសារជាច្រើនក្នុងភូមិ ក្នុងនោះ មានគ្រួសារលោកគីមវ៉ាំងថាញ់ បង្វែរពីដាំដូងតាមបែបបុរាណមកដាំតាមបែបសរីរាង្គ បង្កើនប្រាក់ចំណូលជាង ២០០ លានដុងក្នុងមួយឆ្នាំ។

លោក គីមវ៉ាំងថាញ់ សំណេះសំណាល៖ "ដោយបានក្អួយសុភាពជួយណែនាំ ទើបខ្ញុំប្ដូរពីរបៀបដាំដូងបែបបុរាណមកដាំដូងសរីរាង្គ។ បច្ចុប្បន្ន គ្រួសារខ្ញុំមានប្រាក់ចំណូលស្ថិរភាពជាង ២០០ លានដុងក្នុងមួយឆ្នាំ។ គ្រួសារខ្ញុំ ដឹងគុណក្អួយសុភាពណាស់។

លោកគីមសុភាពប្ដេជ្ញា៖ ខ្ញុំតែងប្ដេជ្ញាខិតខំអនុវត្តល្អ តួនាទី ភារកិច្ចរបស់ខ្លួនជានិច្ច។ខ្ញុំត្រេកអរណាស់ដោយបានរួមដំណើរជាមួយប្រជាជនពង្រីកសេដ្ឋកិច្ចដើម្បីរួមចំណែកកសាងភូមិស្រុកឲ្យកាន់តែរីកចម្រើន។

**ជាស្ពានមេត្រីភាពរវាងគោលចំណងរបស់បក្ស និងទឹកចិត្តប្រជាជន**

អស់ពីចិត្តក្នុងការងារ ជាគំរូក្នុងជីវភាព លោកគីមសុភាព ធ្វើបានល្អតួនាទីជាប្រធានគណៈកម្មការប្រជាជនភូមិ។ លោកដឹកនាំប្រជាជនអនុវត្តបណ្ដាចលនាផង ជាស្ពានមេត្រីភាពរវាងរដ្ឋអំណាចមូលដ្ឋានជាមួយប្រជាជនក្នុងភូមិទៀតផង។ ផ្ដើមពីការងារជាក់ស្ដែង លោកបានរួមចំណែកនាំយកគោលការណ៍ គោលនយោបាយ ច្បាប់របស់បក្ស និងរដ្ឋទៅក្នុងជីវភាពប្រជាជន ដើម្បីកសាងផ្លូងមហាសាមគ្គីក្នុងសហគមន៍។ បច្ចុប្បន្ន ភូមិបត់ថែកមិនត្រឹមតែមានផ្លូវរឹងមាំ ជីវភាពមាមីងក្នុងភូមិក៏កាន់តែរីកចម្រើន។ ក្នុងឆ្នាំ ២០២៤ ប្រាក់ចំណូលមធ្យមរបស់ប្រជាជនម្នាក់ៗសម្រេច ៧៩ លានដុង កើន ០៩ លានដុង បើប្រៀបនឹងឆ្នាំ ២០២៣។ សម្រេចបានលទ្ធផលនោះ មានការរួមចំណែកយ៉ាងសកម្មរបស់លោកគីមសុភាព ជាកម្មាភិបាលមូលដ្ឋាន "ណែនាំប្រជាជនស្ដាប់តាម ធ្វើប្រជាជនជឿ"៕

អត្ថបទ-រូបថត៖ **សុជា**

# បង ថាច់ញៀង គំរូកសិករផលិត-ធ្វើអាជីវកម្មពូកែ

*បងថាច់ញៀង (កើតឆ្នាំ ១៩៦៨) នៅភូមិ ព្រៃកទន្សេង ឃុំង៉ាយទី ជាកសិករខ្មែរមួយរូបបានទទួលស្គាល់កិត្តិនាមផលិត-ធ្វើអាជីវកម្មពូកែថ្នាក់ខេត្ត ជាមួយបណ្ដាទម្រង់ដាំឈើហូបផ្លែ ផលិតស្រូវ និងចិញ្ចឹមគោ។ ផ្ដើមពីទម្រង់នោះ ជារៀងរាល់ឆ្នាំ គ្រួសារបងទទួលបានប្រាក់ចំណូលរាប់រយលានដុង។*



*បង ថាច់ញៀង សំណេះសំណាល ជាមួយតំណាង រដ្ឋអំណាចមូលដ្ឋាន។*

*ជីវភាពធូរធារផ្ដើមពីទម្រង់ឈើហូបផ្លែ*

ក្រោយពេលរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ១៩៨៩ បានឪពុកម្ដាយខាងប្រពន្ធប្រគល់ឱ្យដីស្រែចំនួន ០,៩ ហិកតាសម្រាប់ផលិត។ ជាមួយការប្ដេជ្ញាកែប្រែដីកសិកម្ម បង្កើនតម្លៃផលិត បងបានបង្វែរដីផលិតស្រូវសម្រេចទិន្នផលទាបចំនួន ០,៤ ហិកតាមកដាំក្រូចពោធិ៍សាត់។ រយៈពេលនោះ ក្រូចពោធិ៍សាត់ស្ថិតក្នុងតម្លៃខ្ពស់ ដោយតម្លៃជាង ៣០.០០០ ដុងក្នុងមួយគីឡូក្រាម។ ប្រមូលផលរដូវដំបូង គម្លាតពេលតែងប្រមាណ ២-៣ ថ្ងៃ គ្រួសារបងប្រមូលផលបានប្រមាណ ២០០ គីឡូក្រាម រួចបានឈ្មួញមកទិញដល់ចម្ការ។ ឃើញទម្រង់នេះសមស្រប ជាមួយគ្រួសារ បងបន្តរក្សាទម្រង់នោះរហូតមកទល់សព្វថ្ងៃ ដោយមានផ្ទៃដីកើនឡើងដល់ ១ ហិកតា។

ទន្ទឹមនោះ ពិនិត្យឃើញថា ការរៀបចំដីបម្រុងឱ្យការផលិតស្រូវក៏មានកសិករជាច្រើនមានតម្រូវការ ម្ល៉ោះហើយសន្សំបានប្រាក់ពីទម្រង់ដាំក្រូច បងទិញម៉ាស៊ីនជ្រួយដីមួយគ្រឿងដើម្បីជ្រួយដីឱ្យមាមីងកសិករក្នុងតំបន់ គិតជាមធ្យមក្នុងមួយរដូវៗជ្រួយដីឱ្យកសិករបានប្រមាណ ៦០-៧០ ហិកតា។ ម៉ាស៊ីនជ្រួយដីរបស់គ្រួសារក៏នាំមកប្រាក់ចំណូលឱ្យគ្រួសារបងបង្គួរដែរ។

គិតមកទល់ពេល គ្រួសារបងញៀង មានដីដាំក្រូចពោធិ៍សាត់១ ហិកតា ដីផលិតស្រូវ ១ ហិកតា។ ចំពោះដីស្នងបន្តពីឪពុកម្ដាយក្មេក គ្រួសារបងប្រើប្រាស់ឱ្យការដាំដូង និងដាំស្មៅចិញ្ចឹមគោ។ ជាមួយនឹងទម្រង់រកទទួលទាន់ខាងលើ គិតជាមធ្យម ក្នុងរដូវនីមួយៗទទួលបានប្រាក់ចំណូល ៥០-៦០ លានដុង។ ដោយឡែកចម្ការក្រូចពោធិ៍សាត់ ពេលដែលតម្លៃក្រូចចុះថោក បង្កឱ្យក្រូចចេញផ្លែតាមបែបធម្មជាតិ ដើម្បីអូសអន្លាយអាយុកាលដើមក្រូច ប្រើប្រាស់ជី ថ្នាំការពាររុក្ខជាតិបន្តិចបន្តួចៗល។ដើម្បីរង់ចាំតម្លៃ។

បង ថាច់ញៀង សំណេះសំណាល៖ ជីវភាពបានដូចសព្វថ្ងៃគឺជីវិតត្រូវស៊ូជាមួយភាពលំបាកយ៉ាងច្រើនពីអតីតកាល គាប់ជួនពេលខ្លះមនុស្សជាច្រើនលង់លក់ក្នុងដំណេកយ៉ាងស្រួលនៅពេលរាត្រី រូបខ្ញុំនៅតែបញ្ជេះម៉ាស៊ីនជ្រួយដីឱ្យគេកណ្ដាលវាលស្រែស្ងាត់ជ្រងំ។ ដោយអាស្រ័យខិតខំក្នុងពលកម្ម រៀនសូត្របទពិសោធន៍ពីអ្នកជំនាន់មុនអំពីទម្រង់ បច្ចេកទេសផលិត រូបខ្ញុំកាន់តែទទួលបានជោគជ័យក្នុងការអនុវត្តន៍បណ្ដាទម្រង់។ ក៏ផ្ដើមពីការខិតខំសង្វាតពលកម្ម គ្រួសារសាងសង់បានលំនៅឋានសមរម្យ ប្រកបដោយផាសុកភាពបង្គួរ។

*ជួយគ្នាបង្រីកសេដ្ឋកិច្ច*

បច្ចុប្បន្ន ក្រៅពីការរក្សាទម្រង់ដាំក្រូចពោធិ៍សាត់ គ្រួសារបងនៅទាំងចិញ្ចឹមគោមេបាន ៨ ក្បាល។ ចំនួនគោទាំងនោះ បានគ្រួសារបងបង្កាត់ដោយបណ្ដាប្រភេទពូជគោមានគុណភាព កូនមួយក្បាលក្រោយពេលកើត និងចិញ្ចឹមរយៈ ៤ ខែលក់បានតម្លៃប្រមាណ ១៤ លានដុង។ ចំពោះការចិញ្ចឹមគោក្នុងគ្រួសារ ប្រសិនបើពិនិត្យឃើញគោមានសញ្ញាកើតជំងឺ បងតែងរកថ្នាំព្យាបាលបន្ទាន់។ ដោយមានចំណេះដឹងខាងការចិញ្ចឹមសត្វ បងតែងជួយដល់អ្នកភូមិផង ក៏ដូចជាសមាជិកសមាគមកសិករបង្កើនការបង្ការពីជំងឺមួយចំនួននៅលើគោ បំពេញបន្ថែមចំណីសមស្របសម្រាប់គោតាំងពីពេលចិញ្ចឹមធម្មតា រហូតដល់ដំណាក់កាលគោផើម ដើម្បីជៀសវាងបញ្ហាមិនល្អពេលគោកើតកូន។ ជារៀងរាល់ឆ្នាំ មានសមាជិកសមាគមកសិករ ៧-៨ រូបដែលមិនសូវយល់ពីរបៀបចិញ្ចឹមសត្វ បានបងញៀងជួយណែនាំពីរបៀបថែទាំ ចិញ្ចឹមសត្វយ៉ាងមានប្រសិទ្ធភាព ហើយការចិញ្ចឹមសត្វកាន់តែសម្រេចបានតម្លៃសេដ្ឋកិច្ចខ្ពស់ជាង។

*គិតគូរឱ្យកូនរៀនសូត្របានល្អ*

ជាមួយប្រសិទ្ធភាពពីការអនុវត្តន៍ទម្រង់ គ្រួសារបងនៅទាំងផ្ដុំគិតគូរឱ្យកូនៗរៀនសូត្ររហូតដល់សម្រេចគោលដៅតាមបំណងរបស់ខ្លួន។ បច្ចុប្បន្ន កូនទាំងពីរនាក់របស់គ្រួសារបង សុទ្ធតែបានបញ្ចប់ការសិក្សាមហាវិទ្យាល័យ និងកំពុងបំពេញការងារនៅតាមបណ្ដាផ្នែក៖ កូនស្រីច្បងបំពេញការងារនៅមន្ទីរពេទ្យពហុព្យាបាលតំបន់តាមបិញ កូនស្រីពៅកំពុងបំពេញការងារនៅសាខាធនាគារគោលនយោបាយខេត្តវិញឡុង។ គ្រួសារបងក៏បានសមាគមជំរុញការសិក្សាខេត្តស្ងើចសរសើរជាគ្រួសាររៀនសូត្រ។

លោក ង្វៀងវ៉ាំងយុង ប្រធានសមាគមកសិករឃុំង៉ាយទី មានប្រសាសន៍ឱ្យដឹងថា៖ បង ថាច់ញៀង ជាគំរូកសិករខ្មែរហ៊ានគិត ហ៊ានធ្វើ ឈានមុខក្នុងបណ្ដាចលនាបង្វែរចនាសម្ព័ន្ធពូជដំណាំ សត្វចិញ្ចឹម។ គំរូរបស់លោក សក្ដិសមឱ្យមនុស្សជាច្រើនយកតម្រាប់តាម៕

អត្ថបទ-រូបថត៖ **សម្បត្តិ**

# ចែកអំណោយនិងពិនិត្យជំងឺដោយឥតគិតថ្លៃជូនមាមីងខ្មែរនាឱកាសបុណ្យសែនដូនតា

**ភាឈ**ពីថ្ងៃទី ២០ ខែកញ្ញា មន្ទីរសុខាភិបាលខេត្តវិញឡុងសហការជាមួយមន្ទីរពេទ្យមហាវិទ្យាល័យឱសថសាស្ត្រទីក្រុងហូជីមិញ សាកលវិទ្យាល័យឱសថសាស្ត្រកឹងធើ មន្ទីរពេទ្យ កងទ័ព ១២០ រួមជាមួយបណ្តាមន្ទីរពេទ្យក្នុងខេត្តចាត់តាំងពិនិត្យជំងឺ ពិគ្រោះសុខភាពរួចជូនថ្នាំព្យាបាលជំងឺដោយឥតគិតថ្លៃដល់មាមីងខ្មែរជាង ៤.០០០ នាក់ស្ថិតក្នុងក្របខ័ណ្ឌ គ្រួសារគោលនយោបាយ អ្នកមានស្ថានភាពលំបាក អ្នកមានវ័យចាស់អនាថានៅបណ្តាឃុំ៖ ឡុងហ៊ីប តឹបស៊ើង ត្រាកួងនិងង៉ាយទី។



សមមិត្តហូធីហ្វាងអៀង អនុលេខាអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សខេត្តជូនអំណោយដល់មាមីងខ្មែរនៅឃុំឡុងហ៊ីប។


កងជួរគ្រូពេទ្យ វេជ្ជបណ្ឌិតពិនិត្យ ព្យាបាលជំងឺជូនមាមីងខ្មែរនៅឃុំឡុងហ៊ីប។

នៅឃុំឡុងហ៊ីប សមមិត្តហូធីហ្វាងអៀង អនុលេខាអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សខេត្តវិញឡុង ឧត្តមសេនីយ៍ត្រីង្វៀងមិញទ្រៀវ អគ្គមេបញ្ជាការរងយោធភូមិភាគលេខ ៩ រួមជាមួយបណ្តាសមមិត្តជាសមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សខេត្ត ថ្នាក់ដឹកនាំនៃគណៈកម្មាធិការប្រជាជនខេត្ត គណៈនាយកមន្ទីរសុខាភិបាល បណ្តាផ្នែកចូលរួមពិធីនេះ ។

យោងតាមនោះ មាមីងខ្មែរបានកងជួរគ្រូពេទ្យ វេជ្ជបណ្ឌិតនៃបណ្តាមន្ទីរពេទ្យចាត់តាំងពិនិត្យជំងឺទូទៅ៖ វាស់ចង្វាក់បេះដូង វាស់សម្ពាធឈាម ពិនិត្យគ្រឿងក្នុង ស្បែក ។ល។ គួបផ្សំនឹងការពិគ្រោះសុខភាពរួចផ្តល់ថ្នាំព្យាបាលជំងឺដោយឥតគិតថ្លៃ។ ក្រោយពេលពិនិត្យជំងឺទូទៅ ប្រសិនបើមានការកំណត់របស់វេជ្ជបណ្ឌិត មាមីងនឹងបានឆ្លុះអេកូ វាស់ចង្វាក់ បេះដូង វាស់សម្ពាធឈាម។ល។

ទន្ទឹមនឹងនោះ កងជួរគ្រូពេទ្យ វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ឱសថការី ៥០០ នាក់រួមជាមួយរដ្ឋអំណាចនៃឃុំទាំង ៤ បង្កើនការផ្សព្វផ្សាយសំដៅបង្កើនការយល់ដឹងរបស់ជនរួមជាតិខ្មែរស្តីពីការថែទាំសុខភាព ឧបត្ថម្ភប្រជាជនដំឡើងកម្មវិធីគាំពារសុខាភិបាលលើទូរស័ព្ទដើម្បីសម្រេចការបើកដំណើរការសកម្មភាពបញ្ជីសុខភាពអេឡិចត្រូនិច។

ក្រោយពេលពិនិត្យសុខភាពរួច មាមីងបានទទួលអំណោយមួយចំណែករៀងៗខ្លួនដើម្បីអំណរបុណ្យសែនដូនតា៕

ដំណឹង- រូបថត៖ **ថាច់ហ្វាខ**

# អនុវត្តសេចក្តីសម្រេចចិត្តលេខ ៧២-NQ/TW: យកចិត្តទុកដាក់ថែទាំសុខភាពជូនជនរួមជាតិខ្មែរនាឱកាសបុណ្យសែនដូនតា

*ស្ថិតក្នុងបរិយាកាសជនរួមជាតិខ្មែរនៅណាមបូទទួលអំណរបុណ្យសែនដូនតា ខេត្តវិញឡុងបានចាត់តាំងកម្មវិធីពិនិត្យជំងឺ ផ្តល់ថ្នាំព្យាបាលជំងឺនិងចែកអំណោយដល់មាមីងខ្មែរជាង ៤.០០០ នាក់ស្ថិតក្នុងក្របខ័ណ្ឌគ្រួសារគោលនយោបាយ គ្រួសារមានស្ថានភាពលំបាក ។ សកម្មភាពនេះមិនត្រឹមតែសម្តែងឲ្យឃើញការគិតគូរជាក់ស្តែងរបស់បក្ស រដ្ឋ ថែមទាំងជាជំហានអនុវត្តសេចក្តីសម្រេចចិត្តលេខ ៧២-NQ/TW ចុះថ្ងៃទី ៩/៩/២០២៥ របស់ការិយាល័យនយោបាយស្តីពីវិធីសាស្ត្រទម្លុះទម្លាយមួយចំនួន បង្កើនការការពារ ថែទាំនិងលើកកម្ពស់សុខភាពប្រជាជន។*


*ពិធីជូនអំណោយដល់គ្រួសារក្រីក្រនាឱកាសបុណ្យសែនដូនតា។*

**រួមចែងគិតគូរសុខភាពជនរួមជាតិខ្មែរ**

**នៅ**ថ្ងៃទី ២០ ខែកញ្ញា នៅបណ្តាឃុំ៖ ឡុងហ៊ីប តឹបស៊ើង ត្រាកួងនិងង៉ាយទី មន្ទីរសុខាភិបាលសហការជាមួយមន្ទីរពេទ្យមហាវិទ្យាល័យឱសថសាស្ត្រទីក្រុងហូជីមិញ សាកលវិទ្យាល័យឱសថសាស្ត្រកឹងធើ មន្ទីរពេទ្យកងទ័ព ១២០ និងអង្គភាពជាច្រើនទៀតបានរួមដំណើរការចាត់តាំងកម្មវិធីពិនិត្យ ពិគ្រោះសុខភាពរួចផ្តល់ថ្នាំព្យាបាលជំងឺ និងចែកជូនអំណោយដល់មាមីងខ្មែរជាង ៤.០០០ នាក់។

កម្មវិធីនេះមានវត្តមានរបស់សមមិត្ត ហូធីហ្វាងអៀង អនុលេខាអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សខេត្ត ឧត្តមសេនីយ៍ត្រីង្វៀងមិញត្រៀវ អគ្គមេបញ្ជាការរងយោធភូមិភាគលេខ ៩ ថ្នាក់ដឹកនាំគណៈកម្មាធិការប្រជាជនខេត្ត បណ្តាគណៈ ផ្នែក អង្គការមហាជន។ វត្តមាន របស់ថ្នាក់ដឹកនាំបណ្តាថ្នាក់បានបញ្ជាក់ឲ្យឃើញការប្តេជ្ញានយោបាយក្នុងការលម្អិតបណ្តាគោលការណ៍របស់បក្ស រដ្ឋ បញ្ជូនសេចក្តីសម្រេចចិត្តទៅក្នុងជីវភាពដោយសកម្មភាពជាក់ស្តែង ជិតស្និទ្ធ។

គ្រូពេទ្យ វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា

(អានតទៅទំព័រទី ៧)

# ទឹក ០៥ ប្រភេទបង្ការជំងឺពេលផ្លាស់ប្តូររដូវ

**ជំងឺ**ក្តៅរងារ ឈឺបំពង់ក និងជំងឺដទៃមួយចំនួនតែងកើតឡើងនៅពេលផ្លាស់ប្តូររដូវ។ ពិសាទឹកបន្លែ មើមឈើមួយចំនួននៅរាល់ពេលព្រឹកមិនត្រឹមតែបំប៉នជីវជាតិនៅទាំងជារបាំងធម្មជាតិជួយឲ្យរាងកាយមាំមួន បង្ការជំងឺបានល្អ។

ពេលផ្លាស់ប្តូររដូវ ប្រព័ន្ធស៊ាំនឹងជំងឺតែងខ្សោយបណ្តាលឲ្យកុមារនិងអ្នកមានវ័យចាស់ងាយជ្រាបបណ្តាជំងឺផ្លូវដកដង្ហើម។ ដើម្បីការពារសុខភាព ក្រៅពីរក្សារបបបរិភោគត្រឹមត្រូវ គ្រប់គ្រាន់ ការបំប៉នទឹកពីបន្លែ មើមឈើស្រស់ប្រចាំថ្ងៃជាការជ្រើសរើសសាមញ្ញនិងមានប្រសិទ្ធភាពខ្ពស់។

ពិសាទឹកបន្លែ មើមឈើនៅពេលព្រឹកមិនត្រឹមតែបង្កើនឲ្យប្រព័ន្ធស៊ាំជំងឺនៅទាំងបង្ការបានជំងឺជាច្រើនទៀតដែលតែងកើតមាននៅពេលផ្លាស់ប្តូររដូវ។

បណ្តាប្រភេទទឹកបន្លែ មើមឈើគួរពិសាពេលអាកាសធាតុផ្លាស់ប្តូររដូវ៖

**១. ទឹកមើមផ្ទី**

ពិសាទឹកមើមផ្ទីមានគុណប្រយោជន៍ច្រើនពេលអាកាសធាតុផ្លាស់ប្តូររដូវ។ មើមផ្ទីសម្បូរជាតិលោហធាតុ សារធាតុអុក្សីហ្សែននិងប្រភេទវីតាមីនជាច្រើន។ ពិសាទឹកមើមផ្ទីនៅពេលព្រឹកជួយបង្កើនប្រព័ន្ធធន់ បង្ការបណ្តាជំងឺធ្លាប់ជួបប្រទះពេលអាកាសធាតុផ្លាស់ប្តូររដូវ។ ក្រៅពីនោះ ទឹកនេះនៅទាំងមានគុណប្រយោជន៍ដល់សរសៃឈាមបេះដូង ជួយកែលម្អឈាមខួរក្បាល។

**២. ទឹកមើមស្ពៃបារាំង**

មើមស្ពៃបារាំងសម្បូរជាតិវីតាមីន A,C,K និងបណ្តាធាតុរ៉ែចាំបាច់។ ទឹកមើមស្ពៃបារាំងមិនត្រឹមជួយបង្កើនប្រព័ន្ធធន់ក្នុងដំណាក់កាលផ្លាស់ប្តូររដូវនៅទាំងល្អឲ្យភ្នែក ល្អឲ្យសាច់ស្បែក និងជួយជម្រះជាតិពុលក្នុងសរីរាយ។

**៣. ទឹកផ្លែឈ្លោក**

ផ្លែឈ្លោកមានសារធាតុត្រជាក់ សម្បូរជាតិសរសៃ និងធាតុរ៉ែ។ ពិសាទឹកផ្លែឈ្លោកជួយឲ្យត្រជាក់សរីរកាយ ជម្រះជាតិពុល ទន្ទឹមនឹងនោះជួយកែលម្អផ្លូវរំលាយអាហារ កាត់បន្ថយស្ថានភាពទល់លាមក ពិបាករំលាយអាហារ ទល់លាមក។ នេះជាការជ្រើសរើសសមស្របដើម្បីរក្សាសុខភាពក្នុងបណ្តាថ្ងៃអាកាសធាតុប្រែប្រួលខុសប្រក្រតី។

**៤. ទឹកពីបន្លែប៊ីណា** (bina)

បន្លែប៊ីណាសម្បូរវីតាមីន A,C លោហធាតុ និងធាតុរ៉ែសំខាន់។ ទឹកពីប្រភេទផ្លែឈើនេះជួយបង្កើនប្រព័ន្ធធន់ កែលម្អគុណភាពឈាមអាស្រ័យបង្កើន hemoglobin ទន្ទឹមនឹងនោះ ជួយថែទាំសាច់ស្បែក និងបង្ការទប់ស្កាត់ជំងឺពេលផ្លាស់ប្តូររដូវ។

**៥. ទឹកបន្លែជីអំបើះ**

ទឹកបន្លែជីអំបើះសម្បូរជាតិអុក្សីហ្សែននិងវីតាមីន។ ទឹកបន្លែជីអំបើះមានប្រសិទ្ធភាពក្នុងការជំនួយផ្លូវរំលាយអាហារ បង្កើនប្រព័ន្ធធន់ និងជម្រះជាតិពុលក្នុងសរីរកាយ។ ទន្ទឹមនឹងនោះ ប្រភេទទឹកនេះនៅទាំងជួយឲ្យសាច់ស្បែកភ្លឺរលោង មាំមួនជាង។

ដើម្បីថែរក្សាសុខភាពក្នុងបណ្តាថ្ងៃផ្លាស់ប្តូររដូវ ការបំប៉នទឹកបន្លែស្រស់រាល់ពេលព្រឹកជាការជ្រើសរើសធម្មតាប៉ុន្តែប្រសិទ្ធភាព។ បណ្តាទឹកដូចជាមើមផ្ទី មើមស្ពៃបារាំង ផ្លែឈ្លោក បន្លែប៊ីណា (bina) ឬបន្លែជីអំបើះ មិនត្រឹមជំនួយប្រព័ន្ធធន់ បង្ការជំងឺតម្កាត់នៅទាំងជំនួយផ្លូវរំលាយអាហារ សរសៃឈាមបេះដូង និងល្អឲ្យសាច់ស្បែកទៀតផង។

ការគួបផ្សំជាមួយទម្លាប់នេះនិងរបបបរិភោគតុល្យភាព ដេកគ្រប់ដំណេក និងចលនាសមស្របនឹងជួយឲ្យសរីរកាយមាំមួនសម្របសម្រួលជាមួយអាកាសធាតុប្រែប្រួល៕

**គីមឌុំ៖** *តាមប្រភពសុខភាពនិងជីវភាព*

**ជ្រួត**ជ្រាបស្មារតីថ្លាស់ថ្មី សាខាបក្សភូមិង៉ាបា (ឃុំលីវង៉ីបអាញ់) បានលម្អិតបណ្ដាគោលការណ៍ បទប្បញ្ញត្តិរបស់មជ្ឈិមនិងខេត្ត ដោយទម្រង់ "បក្ខជនល្អ ៤ យ៉ាង សាខាបក្សល្អ ៤ យ៉ាង"។ នេះមិនត្រឹមតែជារបៀបធ្វើប្រកបដោយគំនិតច្នៃប្រតិដ្ឋ សមស្របនឹងភាពជាក់ស្ដែងនៅមូលដ្ឋានឡើយ ថែមទាំងក្លាយជាគំរូក្នុងការងារកសាងបក្ស បង្កើតការយល់ស្របនិង សាយភាយយ៉ាងខ្លាំងក្នុងប្រជាជន។

ចាប់តាំងពីផ្សព្វផ្សាយ សាខាបក្សកំណត់ច្បាស់៖ បក្ខជន "ល្អ ៤ យ៉ាង" ម្នាក់ៗនឹងជាស្នូលដើម្បីសមូហភាពសាខាបក្សសម្រេច "ល្អ ៤ យ៉ាង"។ ស្មារតីនេះបានលម្អិតក្នុងសេចក្ដី សម្រេចចិត្តរៀងរាល់ខែ ភ្ជាប់ជាមួយការវាយតម្លៃ បែងប្រភេទបក្ខជនចុងឆ្នាំ។

ទម្រង់ "បក្ខជនល្អ ៤ យ៉ាង" ផ្ដុំទៅលើខ្លឹមសារ ៤ យ៉ាង៖ សម្រេចល្អភារកិច្ចនយោបាយ គោរពការពិន័យ លក្ខការណ៍របស់បក្ស ផ្សារភ្ជាប់ ស្និទ្ធស្នាលជាមួយប្រជាជន រក្សាការសាមគ្គី ជ្រោងខ្ពស់ស្មារតីទទួលខុសត្រូវ។

ដើម្បីអនុវត្ត សាខាបក្សភូង៉ាបាបានប្រគល់ការងារជាក់ស្ដែងដល់បក្ខជនម្នាក់ៗរួចយកលទ្ធផលសម្រេចភារកិច្ចធ្វើជាលក្ខហានវាយតម្លៃ។ អាស្រ័យហេតុនោះ ស្មារតីបំប៉ន លត់ដំរបស់បក្ខជនពីមួយថ្ងៃទៅមួយថ្ងៃកាន់តែបានលើកកម្ពស់។ មានបក្ខជនច្រើនរូបក្លាយជាគំរូល្អក្នុងពលកម្មផលិត ពង្រីកសេដ្ឋកិច្ចគ្រួសារ ទន្ទឹមនឹងនោះសកម្មចូលរួមការងារសង្គម រួមចំណែកពង្រឹងជំនឿរបស់ប្រជាជនចំពោះបក្ស។

ជាពិសេស បណ្ដាបក្ខជនជាជនជាតិខ្មែរតែងឈានមុខក្នុងការផ្សព្វផ្សាយ បំផុសចលនា មាមីងអនុវត្តគោលការណ៍ គោលមាគ៌ារបស់បក្ស គោលនយោបាយ ច្បាប់របស់រដ្ឋចូលរួមរក្សាសន្តិសុខសណ្ដាប់ធ្នាប់កសាងជីវភាពវប្បធម៌ថ្មីក្នុងភូមិស្រុក។

**សាខាបក្សសាមគ្គី រឹងចាំ**

# សាខាបក្សភូមិង៉ាបា - គំរូក្នុងការងារកសាងបក្សនៅមូលដ្ឋាន



*ទិដ្ឋភាពនៅភូមិង៉ាបា ចាប់តាំងពីពេលមានទម្រង់ "ល្អ ៤ យ៉ាង"។*

យោងលើមូលដ្ឋានបក្ខជន "ល្អ ៤ យ៉ាង" ម្នាក់ៗ សាខាបក្សសន្សឹមៗលើកកម្ពស់គុណភាពប្រជុំជីវភាព រក្សាខ្ជាប់លក្ខការណ៍ប្រមូលផ្ដុំប្រជាធិបតេយ្យ ស្វ័យរិះគន់និងរិះគន់។ បណ្ដាសេចក្ដីសម្រេចចិត្តរបស់សាខាបក្សសុទ្ធតែត្រូវនឹងភាពជាក់ស្ដែង ច្បាមភារកិច្ចពង្រីកសេដ្ឋកិច្ច សង្គម ការពារជាតិ សន្តិសុខនៅមូលដ្ឋាន។

អាស្រ័យហេតុនោះ សាខាបក្សភូមិង៉ាបាអនុវត្តសម្រេចល្អភារកិច្ចច្រើនឆ្នាំបន្តបន្ទាប់ សម្រេចគ្រប់ ៤/៤ លក្ខហាន "សាខាបក្សល្អ ៤ យ៉ាង"៖ សម្រេចភារកិច្ចនយោបាយដោយមានភាគកម្រិតជាច្រើនសម្រេចនិងសម្រេចលើសផែនការដាក់ចេញ កសាងផ្ទៃក្នុងសាមគ្គី ពិន័យម៉ឺងម៉ាត់ កងជួរបក្ខជនគំរូ ទទួលបន្ទុកនិងបានប្រជាជនជឿជាក់ គាំទ្រ។

ទន្ទឹមនឹងនោះ ការងារពង្រីកបក្ខជនក៏សម្រេចបានលទ្ធផលច្រើន។ គិតតែក្នុងឆ្នាំ ២០២៤ សាខាបក្សពង្រីកបក្ខជនថ្មីបានចំនួន ៥ នាក់ ក្នុងនោះមានបក្ខជនជាជនជាតិខ្មែរ បង្កើនចំនួនមកទល់ពេលនេះ សាខាបក្សមានបក្ខជន ៣២ នាក់។ ការងារគ្រប់គ្រង សម្រាំង លើកកម្ពស់គុណភាពបក្ខជនបានអនុវត្តម៉ឺងម៉ាត់ ធានាលក្ខណៈប្រយុទ្ធរបស់អង្គការចាត់តាំងមូលដ្ឋានបក្ស។

ផ្ដើមពីការធ្វើជាគំរូរបស់បក្ខជន ចលនាប្រឡងប្រណាំងស្នេហាជាតិនៅភូមិង៉ាបារីកចម្រើនខ្លាំង។ ប្រជាជនសកម្មចូលរួមកសាងជនបទថ្មី រៀបចំសម្អាតផ្លូវថ្នល់ រក្សាទិដ្ឋភាពបរិស្ថាន។ បណ្ដាទម្រង់សេដ្ឋកិច្ចសមូហភាព ក្រុមប្រិតសំចៃបុលទុន ក្រុមប្រជាស្វ័យការពារ ធ្វើសកម្មភាពពីមួយថ្ងៃទៅមួយថ្ងៃកាន់តែមានប្រសិទ្ធភាព រួមចំណែកកាត់បន្ថយភាពក្រីក្រ បង្កើនប្រភពចំណូលនិងលើកកម្ពស់ជីវភាពប្រជាជន។

ជាពិសេស ជនរួមជាតិខ្មែរក្នុងភូមិមិនត្រឹមតែព្រោមច្រៀងចូលរួម ថែមទាំងក្លាយជាកងកម្លាំងស្នូលទៀតផង។ មាមីងរក្សាអត្តសញ្ញាណវប្បធម៌របស់ខ្លួនតាមរយៈពិធីបុណ្យ ទំនៀមទម្លាប់ប្រពៃណីផង សកម្មកសាងជីវភាពអារ្យធម៌និងពង្រឹងឆ្លងមហាសាមគ្គីទូទាំងជនជាតិផង។

**បន្តពង្រីកនិងបើកទូលាយទម្រង់**

ដើម្បីរក្សានិងពង្រីកសមិទ្ធផលដែលសម្រេចបាន សាខាបក្សភូមិង៉ាបាដាក់ចេញវិធីសាស្ត្រជាច្រើន៖ បន្តជ្រួតជ្រាបគោលដៅទម្រង់ "ល្អ ៤ យ៉ាង"។ បង្កើនការបំប៉នទ្រឹស្ដីនយោបាយ បង្កើនលទ្ធភាពការងារជូនបក្ខជនវ័យក្មេងនិងបក្ខជនជនជាតិខ្មែរ។ រក្សាវិន័យ ក្រឹត្យក្រមក្នុងការប្រជុំជីវភាពសាខាបក្ស។ ទន្ទឹមនឹងនោះ ឧស្សាហ៍ត្រួតពិនិត្យ វាយតម្លៃ ស្ញើចសរសើរទាន់ពេលកត្តាដែលសកម្មនិងក្រើនរំលឹកចំណុចដែលនៅខ្សោយ។

បទពិសោធន៍ដកចេញពីភាពជាក់ស្ដែងបង្ហាញឲ្យឃើញថា ពេលបក្ខជនម្នាក់ៗជាគំរូពិតប្រាកដ សាខាបក្សនឹងសាមគ្គី រឹងមាំ។ ពេលសាខាបក្សរឹងមាំ ប្រជាជនជឿជាក់ យល់ស្រប។ នេះគឺជាគ្រឹះធារដ៏រឹងមាំដើម្បីប្រព័ន្ធនយោបាយនៅមូលដ្ឋានមាំមួន បង្កើតជាថាមពលជំរុញការពង្រីកសេដ្ឋកិច្ច សង្គមនៅមូលដ្ឋាន។

អាចបញ្ជាក់បានថា ទម្រង់ "បក្ខជនល្អ ៤ យ៉ាង សាខាបក្សល្អ ៤ យ៉ាង" នៅភូមិង៉ាបាជាសក្ខីភាពរស់រវើកសម្រាប់ប្រសិទ្ធភាពការងារកសាងបក្សពីមូលដ្ឋាន។ ជាមួយរបៀបធ្វើត្រឹមត្រូវ មានរបៀបរៀបរយ ស្របនឹងភាពជាក់ស្ដែង ទម្រង់មិនត្រឹមតែលើកកម្ពស់លទ្ធភាពដឹកនាំ កម្លាំងប្រយុទ្ធរបស់អង្គការមូលដ្ឋានបក្សឡើយ នៅទាំងរួមចំណែកពង្រឹងជំនឿរបស់ប្រជាជន បង្កើតជាកម្លាំងរីករាលដាលខ្លាំងក្នុងសហគមន៍។

ផ្ដើមពីគំរូនៅភូមិង៉ាបា អាចពង្រីកទូលាយទម្រង់នេះចេញទៅសាខាបក្សផ្សេងហើយញ៉ាំងឲ្យទម្រង់ "ល្អ ៤ យ៉ាង" ក្លាយជាចលនាស៊ីជម្រៅ ពិតប្រាកដ រួមចំណែកកសាងបក្ខភាគ ឃុំលីវង៉ីបអាញ់ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែស្អាតស្អំ រឹងមាំ បំពេញតម្រូវការភារកិច្ច ក្នុងដំណាក់កាលថ្មី៕

អត្ថបទ-រូបថត៖ **ថាច់ហ្វាខ**

*សាខាបក្សភូមិង៉ាបាមានបក្ខជន ៣២ នាក់ក្នុងនោះបក្ខជននារី៤ នាក់និងបក្ខជនខ្មែរ ៦ នាក់។ បក្ខជនទាំងអស់សុទ្ធសឹងចុះឈ្មោះអនុវត្តទម្រង់ "បក្ខជនល្អ ៤ យ៉ាង"។ សាខាបក្សសម្រេចល្អភារកិច្ច សម្រេចគ្រប់ ៤/៤ លក្ខហាន "សាខាបក្សល្អ ៤ យ៉ាង" ច្រើនឆ្នាំ បន្តបន្ទាប់។*

# អនុវត្តសេចក្ដីសម្រេចចិត្តលេខ ៧២-NQ/TW: យកចិត្តទុកដាក់...

*(តមកពីទំព័រទី៦)*

ឱសថការីជាង ៥០០ នាក់រួមជាមួយកងកម្លាំងសុខាភិបាលមូលដ្ឋានបានពិនិត្យធម្មតា វាស់សម្ពាធឈាម ឆ្លុះអេកូ ថតរូប X-quang ពិនិត្យជាតិស្ករក្នុងឈាម វាស់ចង្វាក់បេះដូង ពិគ្រោះព្យាបាលជំងឺ។ល។ ជួយឲ្យមាមីងបានប្រសព្វជាមួយសេវាកម្មសុខាភិបាលទំនើបនៅលើភូមិសាស្ត្រ។ ទន្ទឹមនឹងនោះ កងជួរសុខាភិបាលនៅទាំងគួបផ្សំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្ដីពីបង្ការជំងឺ លើកទឹកចិត្តប្រជាជនឲ្យចូលរួមគាំពារសុខាភិបាលនិងប្រើប្រាស់ឱសថផលក្នុងការថែទាំសុខភាព។

**ភ្ជាប់ជាមួយសេចក្ដីសម្រេចចិត្តលេខ ៧២-NQ/TW**

ចំណុចលេចធ្លោនៃកម្មវិធីនោះគឺផ្សារភ្ជាប់ស្អិតល្មួតជាមួយស្មារតីសេចក្ដីសម្រេចចិត្តលេខ ៧២-NQ/TW របស់ការិយាល័យនយោបាយស្ដីពី "វិធីសាស្ត្រទម្លុះទម្លាយមួយចំនួន បង្កើនការការពារ ថែទាំនិងលើកកម្ពស់សុខភាពប្រជាជន"។ ខ្លឹមសារក្នុងសេចក្ដីសម្រេចចិត្តបញ្ជាក់ច្បាស់ សុខភាពគឺជាដើមទុនដ៏សំខាន់បំផុត ជាលក្ខណៈសម្រេចចម្បងដើម្បីលើកកម្ពស់គុណភាពជីវភាព ពង្រីកសេដ្ឋកិច្ច សង្គម ពង្រឹងកិច្ចការពារជាតិ សន្តិសុខ។

សកម្មភាពនៅខេត្តវិញឡុងបានលម្អិតទស្សនៈនោះដោយសកម្មភាព៖ ប្រជាជនគ្រប់រូប តែងបានប្រសព្វជាមួយសេវាកម្មសុខាភិបាលតាមពេលកំណត់ បានថែទាំសុខភាពលើកដំបូង បានពិគ្រោះលើកកម្ពស់រាងកាយនិងស្មារតី។ នេះក៏ជាសក្ខីភាពបង្ហាញឲ្យឃើញច្បាស់ស្មារតី "មិនទុកឲ្យនរណាម្នាក់នៅពីក្រោយខ្នង" ក្នុងការងារថែទាំសុខភាពទូទាំងប្រជាជន។

ទន្ទឹមនឹងកងជួរសុខាភិបាល មានអាជីវកម្មអង្គការចាត់តាំងសង្គមជាច្រើនទៀតបានរួមដំណើរ ឧបត្ថម្ភ លេចធ្លោដូចជា៖ ប្រព័ន្ធអ្នកលក់ឱសថឡុងចូវ ធនាគារ Agribank វិញឡុងជាដើម។ ការចូលរួមនេះបង្ហាញឲ្យឃើញស្មារតីសង្គមូបនីយកម្មសុខាភិបាល ប្រមូលកម្លាំងចម្រុះដើម្បីអនុវត្តសម្រេចជោគជ័យសេចក្ដីសម្រេចចិត្តលេខ ៧២ របស់ការិយាល័យនយោបាយ។

**ជំនឿនិងការផ្សារភ្ជាប់ជាមួយបក្ស**

បច្ចុប្បន្ននេះ ខេត្តវិញឡុងមានប្រជាជនជាង ៤,២ លាននាក់ ក្នុងនោះជាង ៨% ជាជនជាតិខ្មែរ។ អាស្រ័យការយកចិត្តទុកដាក់របស់បក្ស រដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ ជីវភាពរបស់បក្សជនរួមជាតិខ្មែរក្នុងខេត្តពីមួយថ្ងៃទៅមួយថ្ងៃកាន់តែបានកែលម្អ។ អត្រាគ្រួសារក្រីក្រក្នុងតំបន់ជនរួមជាតិខ្មែរនៅតែ ១,៦% (ស្មើនឹង ១.៦១៩ គ្រួសារ)គ្រួសារជិតក្រនៅ៣,២% (ជាង ៣.០០០ គ្រួសារ)។ ទន្ទឹមនឹងនោះ បណ្ដាចលនាប្រឡងប្រណាំងស្នេហាជាតិ បណ្ដាសកម្មភាពសាសនា វប្បធម៌ភ្ជាប់ជាមួយប្រពៃណីបុណ្យសែនដូនតាបង្កបានជាថាមពលជំរុញស្មារតីដ៏ធំ ពង្រឹងឆ្លងមហាសាមគ្គីទូទាំងជនជាតិ។

នៅបណ្ដាថ្ងៃ ២១– ២៣ ខែកញ្ញា នៅតាមបណ្ដាវត្តខ្មែរលើភូមិសាស្ត្រខេត្ត សកម្មភាពជំនឿសាសនា វប្បធម៌ សិល្បៈវិសេសជាច្រើនបានចាត់តាំងឡើង ឆ្លុះបញ្ចាំងឲ្យឃើញលក្ខណអត្តសញ្ញាណជាតិ។ ការចាត់តាំងពិនិត្យ ព្យាបាលជំងឺ ថែទាំសុខភាពក្នុងឱកាសនេះបានបង្កើតបន្ថែមក្ដីរីករាយ ការផ្សារភ្ជាប់ ជឿជាក់របស់ជនរួមជាតិខ្មែរចំពោះការដឹកនាំរបស់បក្ស រដ្ឋ។

អាចបញ្ជាក់បានថា កម្មវិធីពិនិត្យ ជូនថ្នាំព្យាបាលជំងឺដោយឥតគិតថ្លៃនិងចែកជូនអំណោយដល់ជនរួមជាតិខ្មែរនៅខេត្តវិញឡុងមិនត្រឹមតែជាសកម្មភាពប្រកបដោយលក្ខណមនុស្សសាស្ត្រ ពោរពេញអត្ថន័យក្នុងឱកាសបុណ្យសែនដូនតា នៅទាំងជាជំហានជាក់ស្ដែង មានភាពរស់រវើកក្នុងការអនុវត្តន៍សេចក្ដីសម្រេចចិត្តលេខ ៧២-NQ/TW របស់ការិយាល័យនយោបាយ។ ពេលសេចក្ដីសម្រេចចិត្តបានទៅដល់ជីវភាពប្រជាជនគ្រប់រូប សហគមន៍នីមួយៗតែងបានថែទាំសុខភាពគ្រប់ជ្រុងជ្រោយ បង្កើតបានជាគ្រឹះធាររឹងមាំសម្រាប់ការអភិវឌ្ឍន៍និរន្តរភាព។

នោះក៏ជាសក្ខីភាពឲ្យស្មារតី "យកប្រជាជនធ្វើជាមជ្ឈមណ្ឌល" ដើម្បីរាល់គោលនយោបាយរបស់បក្សសុទ្ធតែបានផ្ដើមប្រភពពីជីវភាព វិលមកបម្រើជីវភាព នាំមកផលប្រយោជន៍ ជាក់ស្ដែងជូនប្រជាជន ក្នុងនោះ មានជនរួមជាតិខ្មែរនៅណាមបូ អ្នកដែលកំពុងរួមកម្លាំង កសាងមាតុភូមិពីមួយថ្ងៃទៅមួយថ្ងៃឲ្យកាន់តែសម្បូររុងរឿង៕

អត្ថបទ- រូបថត៖ **ថាច់ហ្វាខ**

